ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

អនាគតនៃ
ទីផ្សារការងារនៅកម្ពុជា




## ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ

# តម្រូវការកម្លាំងពលកម្មលើទីផ្សារការងារ ក្នុងបរិបទជំងឺកូវីដ-១៩

ឆ្នាំទី ១
លេខ ៣

# ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ

## អារម្ភកថា

ចាប់តាំងពីដើមឆ្នាំ២០២០ រហូតដល់ពាក់កណ្តាលឆ្នាំ២០២១ នេះ កម្ពុជា ក៏ដូចជាបណ្តាប្រទេសលើពិភពលោកបាននិងកំពុងទទួលរងនូវផលប៉ះពាល់អវិជ្ជមាននៃជំងឺរាតត្បាតជាសកលកូវីដ-១៩ មកលើបញ្ហាសុខភាពសាធារណៈសេដ្ឋកិច្ចសង្គម ការអប់រំ និងបណ្តុះបណ្តាល និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ការបាត់បង់ការងារជាច្រើនហើយថែមទាំងបន្ទុចបង្អាក់ដល់ការអភិវឌ្ឍឈានឡើងរបស់កម្ពុជាផងដែរ។ ជំងឺកូវីដ-១៩ បានកើតឡើងផលប៉ះពាល់ដែលមិនធ្លាប់មានពីមុនមកលើទីផ្សារការងារកម្ពុជា ទាំងដោយផ្ទាល់តាមរយៈវិធានការបិទខ្ទប់ ការព្យួរកិច្ចសន្យាការងារ ការបញ្ឈប់ការងារ និងតាមរយៈការធ្លាក់ចុះនៃតម្រូវការសរុប និងការផ្គត់ផ្គង់ការរំខានខ្សែសង្វាក់។ វិស័យដែលរងផលប៉ះពាល់ខ្លាំងបំផុតទាក់ទងនឹងការបាត់បង់ការងារដែលបានព្យាករណ៍គឺ សំណង់ ផលិតកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន ការដឹកជញ្ជូន ការផ្ទុក និងទំនាក់ទំនង។ ស្របជាមួយគ្នាស្ថានភាពនេះដែរ នៅសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ក្រុមហ៊ុនឯកជន ក៏បានជួបប្រទះនឹងបញ្ហាកង្វះជំនាញ និងគម្លាតជំនាញ ដែលទាមទារឱ្យមានការបណ្តុះបណ្តាលបន្ថែម និងបណ្តុះបណ្តាលឡើងវិញ ដើម្បីបំពេញតម្រូវការដែលកំពុងខ្វះខាត។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បានពង្រីកការបណ្តុះបណ្តាលបន្ថែមទាំងវគ្គខ្លី និងវគ្គវែង ជាពិសេសការផ្តល់វគ្គបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ (C1) ពិសេស ជូនដល់កម្មករនិយោជិតដែលបាត់បង់ការងារ និងព្យួរកិច្ចសន្យាការងារ ដើម្បីទទួលបានជំនាញបច្ចេកទេស និងវិជ្ជាជីវៈមួយច្បាស់លាស់សម្រាប់ឱកាសការងារថ្មី និងអាចប្រកបការងារដោយខ្លួនឯងបាន។

ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារកម្ពុជាក្នុងលេខ ៣ នេះ នឹងចូលរួមចំណែកមួយជាមគ្គុទ្ទេសក៏និងត្រីវិស័យសម្រាប់តម្រង់ទិសដល់យុវជនក្នុងការសម្រេចចិត្តជ្រើសរើសជំនាញសិក្សា និងត្រៀមខ្លួនចូលទៅកាន់ទីផ្សារការងារកម្ពុជានាពេលអនាគត។សៀវភៅនេះបានបង្ហាញឃើញពីស្ថានភាពទូទៅនៃទីផ្សារការងារកម្ពុជា ការព្យាករណ៍ពីតម្រូវការអ្នកបច្ចេកទេសក្នុងទីផ្សារការងារនិងជំនាញកំពុងធ្វើការបណ្តុះបណ្តាលក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

នាយកដ្ឋានព័ត៌មានទីផ្សារការងារ នៃអគ្គនាយដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ នេះឡើង ដើម្បីជាប្រយោជន៍ដល់សាធារណជនទូទៅជាពិសេសយុវជនឱ្យបានស្វែងយល់អំពីព័ត៌មានពីជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងតម្រូវការកម្លាំងពលកម្មនៅលើទីផ្សារការងារកម្ពុជាបង្កើនភាពងាយស្រួលដល់ការចាប់យកជំនាញវិជ្ជាជីវៈរបស់យុវជន និងតម្រូវការផ្សារការងារកម្ពុជា។

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ



# ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ

## មាតិកា


• អារម្ភកថា

• បញ្ជីរូបភាព និងតារាង

• អក្សរកាត់

| | ទំព័រ |
|---|---|
| I. ស្ថានភាពទូទៅនៃប្រជាជន | ១ |
| ១-ស្ថិតិប្រជាជនក្នុងវ័យសិក្សាមិនទាន់មានការងារ | ២ |
| ២-ស្ថិតិប្រជាជនគ្រប់អាយុចូលបំពេញការងារ | ២ |
| ៣-ស្ថិតិប្រជាជនមានអាយុចូលនិវត្តន៍ | ២ |
| II. ទីផ្សារការងារ | ៣ |
| ១-ស្ថិតិការងារ | ៣ |
| ២-តម្រូវការទីផ្សារការងារ | ៤ |
| ៣-ទីផ្សារការងារតាមវិស័យសេដ្ឋកិច្ច | ៥ |
| III. តម្រូវការកម្លាំងពលកម្ម | ៦ |
| ១-កំណើនកម្លាំងពលកម្មក្នុងទីផ្សារការងា | ៦ |
| ២-តម្រូវការការងារ | ៦ |
| ៣-កំណើនកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច | ៦ |
| IV. តម្រូវការបណ្តុះបណ្តាលកម្លាំងពលកម្មតាមវិស័យ | ១០ |
| ១-ស្ថិតិសិស្ស និស្សិត | ១០ |
| ២-ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ១៤ |
| ២.១ - សិក្ខាកាម សិស្ស និស្សិតរៀនជំនាញបច្ចេកទេស | ១៤ |
| ២.២ - ការសិក្សាជំនាញបច្ចេកទេសតាមវិស័យ | ១៧ |
| ៣-ប្រព័ន្ធជាតិបអប់រំណ្តុះបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform) | ១៩ |



**គណៈគ្រប់គ្រង**

ឯកឧត្តមបណ្ឌិត ពេជ សោភ័ន

ឯកឧត្តម ប៉ុក ផាន់

ឯកឧត្តម ឡៅ ហ៊ីម

ឯកឧត្តម ទេព ណារី

ឯកឧត្តម ហ៊ីង ស៊ីផេត

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ថង សាម៉ុន

**នាយកនិពន្ធ**

លោកស្រី សៅ សុគន្ធកេត្យា

**នាយករងនិពន្ធ**

លោក យស ធីរិទ្ធ

លោក ចាន់ សារុធ

លោក ងួន ភុនពិសី

លោក គិត សុភាព

លោក ឈាង ចន្ទា

**កវីនិពន្ធ និងអ្នករចនាអត្ថបទ**

លោក ងួន ភុនពិសី

លោក ភួង រ័ត្នសុធា

លោក ទេព សេងហ៊ន

លោក សុខ ធម្មភាសី

លោក ភឿន ផារី

**ផ្នែករូបភាព និងកុំព្យូទ័រ**

លោក គិត សុភាព

លោក ឈាង ចន្ទា

លោក គុល សុខគ័ង

លោក ប៊ុនធឿន អរុណរតនៈ

**ផ្នែកពិនិត្យ និងកែសម្រួលអក្ខរាវិរុទ្ធ**

លោក យស ធីរិទ្ធ

លោក ចាន់ សារុធ

លោកស្រី លី សុខសម្បត្តិ

លោក សាយ ស៊ីមាន

លោក គន់ កាន់ណា

V. ការផ្គត់ផ្គង់កម្លាំងពលកម្មលើទីផ្សារការងារ ................ ២១

១-ស្ថានភាពទីផ្សារការងារ.................................. ២១

២-ការកើនឡើងការងារនៅឆ្នាំ២០២០ ...................... ២៣

៣-កង្វះជំនាញតាមវិស័យ ................................ ២៥

៤-កង្វះជំនាញ ........................................... ២៧

៥-គម្លាតជំនាញ........................................... ២៩

VI. សេចក្តីសន្និដ្ឋាន ............................................. ៣១

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ព័ត៌មានអាហារូបករណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ សម្រាប់ឆ្នាំសិក្សា ២០២១-២០២២

ឧបសម្ព័ន្ធទី២៖ បញ្ជីឈ្មោះសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ក្រុមហ៊ុនឯកជនមានតម្រូវការកម្លាំងពលកម្ម២០២១

ឯកសារយោង

# បញ្ជីរូបភាព និងតារាង

## ក. បញ្ជីរូបភាព


រូបភាពទី១៖ ចំនួនប្រជាជនតាមអាយុ និងភេទ ..... ១

រូបភាពទី២៖ ក្រុមអាយុក្រោម ១៥ឆ្នាំ ..... ២

រូបភាពទី៣៖ ភាគរយប្រជាជនតាមវ័យ ..... ២

រូបភាពទី៤៖ តម្រូវការការងារក្នុង ១ឆ្នាំ ..... ៦

រូបភាពទី៥៖ ស្ថានភាពនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យក្នុងឆ្នាំសិក្សា ២០១៩-២០២០ ..... ១៣

រូបភាពទី៦៖ ស្ថានភាពនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យក្នុងឆ្នាំសិក្សា ២០១៩-២០២០ ..... ១៣

រូបភាពទី៧៖ សិក្ខាកាម សិស្ស និស្សិត បានបញ្ចប់ការសិក្សាតាមវិស័យអាទិភាពឆ្នាំសិក្សា ២០២០-២០២១ ..... ១៨

រូបភាពទី៨៖ ចំណែកនៃគ្រឹះស្ថានសហគ្រាសតាមវិស័យ និងប្រភេទនៃការកែច្នៃរយៈពេល៣ឆ្នាំចុងក្រោយដល់ចុងឆ្នាំ២០១៩ ..... ២២

រូបភាពទី៩៖ ចំណែកនៃគ្រឹះស្ថានសហគ្រាសដែលទទួលបានចំណូលការងារយ៉ាងហោចណាស់១តាមវិស័យ ..... ២៣

រូបភាពទី១០៖ ចំណែកនៃគ្រឹះស្ថានសហគ្រាសដែលបានរាយការណ៍អំពីការងារដែលខ្វះជំនាញ (% គ្រឹះស្ថានសហគ្រាសដែលទទួលបានការងារយ៉ាងហោចណាស់១) តាមវិស័យ ..... ២៥

រូបភាពទី១១៖ ចំណែកគ្រឹះស្ថានសហគ្រាសដែលរងផលប៉ះពាល់ដោយគម្លាតជំនាញតាមវិស័យ ..... ២៧

រូបភាពទី១២៖ កត្តាដែលបង្កើតឱ្យមានគម្លាតជំនាញ ..... ២៩

រូបភាពទី១៣៖ ការត្រៀមខ្លួនរបស់កម្មករនិយោជិតក្នុងការដោះស្រាយបម្រែបម្រួលផលប៉ះពាល់ដល់ដំណើរការការងារក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ តាមវិស័យ ..... ៣០


## ខ. បញ្ជីតារាង


តារាងទី១៖ ចំនួនប្រជាជនតាមអាយុ ..... ១

តារាងទី២៖ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ តាមមុខរបរ ..... ៤

តារាងទី៣៖ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធតាមសកម្មភាពសេដ្ឋកិច្ច ..... ៥

តារាងទី៤៖ ការងារសរុប តាមភេទ និងវិស័យសេដ្ឋកិច្ច ឆ្នាំ ២០០៧-២០២០ ..... ៧
តារាងទី៥៖ ការងារតាមវិស័យសេដ្ឋកិច្ច និងភេទ ឆ្នាំ២០០៧-២០២០ (ភាគរយ) ..... ៨
តារាងទី៦៖ បម្រែបម្រួលនិងកំណើនការងារតាមវិស័យសេដ្ឋកិច្ច ឆ្នាំ២០០៧-២០២០ ..... ៩
តារាងទី៧៖ អត្រាលំហូរសិស្ស ..... ១១
តារាងទី៨៖ អត្រាបញ្ចប់កាសិក្សាឆ្នាំសិក្សា ២០១៩-២០២០ និង ២០២០-២០២១ ..... ១១
តារាងទី៩៖ ស្ថិតិមធ្យមសិក្សាប្រៀបធៀបរវាងឆ្នាំសិក្សា ២០១៩-២០២០និង ២០២០-២០២១ ..... ១២
តារាងទី១០៖ អត្រាលំហូរសិស្សនៅមធ្យមសិក្សារវាងឆ្នាំសិក្សា ២០១៨-២០១៩និង ២០១៩-២០២០ ..... ១២
តារាងទី១១៖ ស្ថានភាពនិស្សិតកំពុងសិក្សា និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យក្នុងឆ្នាំសិក្សា ២០១៩-២០២០ ..... ១៣
តារាងទី១២៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិតបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថា អ.ប.វ.ឆ្នាំសិក្សា ២០២០-២០២១
ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០ ..... ១៥
តារាងទី១៣៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សាតាមកម្រិតគុណវុឌ្ឍិជាតិកម្ពុជា ឆ្នាំសិក្សា ២០២០-២០២១
ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០ ..... ១៦
តារាងទី១៤៖ ស្ថិតិសិក្ខាកាម បានបញ្ចប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈតាមប្រភេទកម្មវិធីផ្សេងៗសិក្សា ២០២០-២០២១
ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០ ..... ១៧
តារាងទី១៥៖ ផលប៉ះពាល់ការងារតាមវិស័យដោយជំងឺកូវីដ-១៩ នៅកម្ពុជា ..... ២១
តារាងទី១៦៖ ឧប្បត្តិហេតុ និងការបែងចែកចំណូលការងារតាមវិស័យ ..... ២៤
តារាងទី១៧៖ មុខរបរអាទិភាព ៦ ដែលខ្វះជំនាញតាមវិស័យ (ISCO_3digits) ..... ២៦
តារាងទី១៨៖ មុខរបរអាទិភាព ៦ ដែលមានគម្លាតជំនាញ (ISCO_3digits) ..... ២៨

# អក្សរកាត់

| | | |
|---|---|---|
| អ.ប.វ. | = | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| TVET | = | Technical Vocational Education and Training |
| TVETSDP | = | Technical Vocational Education and Training Sector Development Project |
| ADB | = | Asia Development Bank |
| NEA | = | National Employment Agency |
| ILO | = | International Labour Organization |
| TVETMIS | = | Technical Vocational Education and Training Management Information System |
| ICT | = | Information and Communication Technology |
| NIS | = | National Institute of Statistics |
| ISCO | = | International Standard Industrial Classification |
| C1, C2, C3 | = | Technical Vocational Certificate 1, 2, 3 ( សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១, ២, ៣ ) |
| ប៊ីប | = | កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណេត |
| BEEP | = | Basic Education Equivalency Program |

# I. ស្ថានភាពទូទៅនៃប្រជាជនកម្ពុជា

កម្ពុជាមានប្រជាជនប្រមាណជាង ១៥.៥លាននាក់ ឬស្មើនឹងចំនួនសរុប ១៥ ៥៥២ ២១១នាក់ និងមានអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំចំនួន ១.៤% នេះបើយោងតាមរបាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយក្នុងសៀវភៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដែលបានផ្សាយចេញជាផ្លូវការ នៅខែតុលា ឆ្នាំ២០២០។ ទិន្នន័យជំរឿនក៏បង្ហាញថា ទៅថ្ងៃអនាគតកម្ពុជាជាប្រទេសដែលមានប្រជាជនវ័យចាស់កាន់តែច្រើន។

លទ្ធផលជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ មានចំនួនជាង ១៥.៥លាននាក់ ប្រុសមានចំនួន៧.៥លាននាក់ ធៀបនឹងលទ្ធផលជំរឿនឆ្នាំ២០០៨ ប្រជាជនកម្ពុជាបានកើនឡើងចំនួន ២.២លាននាក់។ ទិន្នន័យបានបង្ហាញដែរថា រាជធានី ខេត្តចំនួន៤ មានប្រជាជន ច្រើនជាង ១លាននាក់ គឺរាជធានីភ្នំពេញមានប្រជាជនប្រមាណ ២.៣លាននាក់ ខេត្តកណ្ដាល ១.២លាននាក់ ខេត្តព្រៃវែង ១.១លាននាក់ និងខេត្តសៀមរាបមានប្រជាជនប្រមាណ១លាននាក់។ បើប្រៀបធៀបជំរឿនក្នុងឆ្នាំ២០១៩ និងឆ្នាំ២០០៨ ប្រជាជនវ័យក្មេង ដែលមានអាយុពី ០ឆ្នាំ ទៅ ១៤ឆ្នាំ មានការធ្លាក់ចុះពី ៣៣% ទៅ ២៩.៤% ហើយប្រជាជនវ័យកណ្ដាល (១៥-៥៩ឆ្នាំ) បានកើនឡើង ពី ៦០% ទៅ ៦១.៧% និងមនុស្សចាស់ចាប់ពី ៦០ឆ្នាំឡើង បានកើនឡើងពី ៦.៣% ទៅ ៨.៩%។ តួលេខទាំងនេះបង្ហាញថា ប្រជាជនកម្ពុជាកំពុងចាប់ផ្ដើមវិវត្តន៍ទៅតាមអាយុ ពោលគឺកម្ពុជាប្រទេសមានប្រជាជនវ័យចាស់ច្រើននៅពេលអនាគត។

តារាងទី១៖ ចំនួនប្រជាជនតាមអាយុ

| ចំនួនប្រជាជនគិតជាភាគរយតាមអាយុ | | | |
|---|---|---|---|
| អាយុ | សរុប | ប្រុស | ស្រី |
| 0-4 ឆ្នាំ | 9.3 | 9.9 | 8.8 |
| 5-9 ឆ្នាំ | 9.5 | 10.0 | 9.0 |
| 10-14 ឆ្នាំ | 10.6 | 11.1 | 10.1 |
| 15-19 ឆ្នាំ | 9.1 | 9.4 | 8.8 |
| 20-24 ឆ្នាំ | 8.1 | 8.1 | 8.1 |
| 25-29 ឆ្នាំ | 9.2 | 9.2 | 9.1 |
| 30-34 ឆ្នាំ | 8.4 | 8.4 | 8.3 |
| 35-39 ឆ្នាំ | 8.4 | 8.5 | 8.3 |
| 40-44 ឆ្នាំ | 4.8 | 4.8 | 4.8 |
| 45-49 ឆ្នាំ | 5.1 | 5.0 | 5.1 |
| 50-54 ឆ្នាំ | 4.6 | 4.4 | 4.8 |
| 55-59 ឆ្នាំ | 4.1 | 3.9 | 4.3 |
| 60-64 ឆ្នាំ | 3.0 | 2.5 | 3.5 |
| 65-69 ឆ្នាំ | 2.3 | 1.9 | 2.7 |
| 70-74 ឆ្នាំ | 1.6 | 1.3 | 1.8 |
| 75+ | 2.0 | 1.6 | 2.4 |

រូ.ទី១៖ ចំនួនប្រជាជនតាមអាយុ និងភេទ



## ១-ស្ថិតិប្រជាជនក្នុងវ័យសិក្សាមិនទាន់មានការងារ

ប្រជាជនក្នុងវ័យមិនទាន់មានការងារក្នុងនិយមន័យនេះ គឺសំដៅទៅលើប្រជាជនដែលស្ថិតក្នុងវ័យកំពុងសិក្សាមិនទាន់ចេញរកការងារ ឬមិនទាន់មានការងារធ្វើ។ ក្នុងនិយមន័យនេះ យើងកំណត់យកប្រជាជនដែលស្ថិតក្នុងវ័យកុមារ គឺរាប់ពីអាយុក្រោម ១៥ឆ្នាំ។ តាមតួរលេខនៃជំរឿនឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ប្រជាជនដែលមានអាយុក្រោម១៥ឆ្នាំ សរុបមានចំនួន(១) ២៩.៤% ស្មើនឹងចំនួនប្រជាជនប្រមាណជា ៤ ៥៧២ ៣៥០នាក់ ស្រីមានចំនួន ២៧.៩% ស្មើនឹងចំនួនប្រជាជនប្រមាណជា ២ ៣២៥ ០៦២នាក់ នៃចំនួនប្រជាជនស្រីសរុបទូទាំងប្រទេស។

## ២-ស្ថិតិប្រជាជនគ្រប់អាយុចូលបំពេញការងារ

ទិន្នន័យប្រជាជនគ្រប់អាយុចូលបំពេញការងារក្នុងនិយមន័យនេះ កំណត់យកប្រជាជនដែលមានអាយុ ១៥ឆ្នាំឡើងរហូតដល់អាយុ៥៩ឆ្នាំ។ តាមទូរលេខប្រជាជនដែលមានអាយុ ១៥ឆ្នាំឡើង រហូតដល់អាយុ៥៩ឆ្នាំ ក្នុងជំរឿនឆ្នាំ២០១៩ យើងសង្កេតឃើញថា មានចំនួនប្រជាជនប្រមាណជា ៦១.៧% ឬស្មើនឹងចំនួនប្រជាជន ៩ ៥៩៥ ៧១៤នាក់ ក្នុងនោះស្រីមានចំនួន៦១.៦% ឬស្មើនឹងចំនួនប្រជាជនជាង ៤ ៨៧១ ៥៥៨នាក់ នៃចំនួនប្រជាជន ៤ ៥៧២ ៣៥០នាក់ ស្រីមានចំនួន ២៧.៩% ស្មើនឹងចំនួនស្រីសរុបទូទាំងប្រទេស។

រូ.ទី២៖ ក្រុមអាយុក្រោម ១៥ឆ្នាំ




(១) សៀវភៅជំរឿនឆ្នាំ២០១៩ ចេញផ្សាយក្នុងខែតុលា ឆ្នាំ២០២០ ទំព័រ៣៩

## ៣-ស្ថិតិប្រជាជនមានអាយុចូលនិវត្តន៍

ប្រជាជនដែលមានអាយុចូលនិវត្តន៍ គឺជាចំនួនប្រជាជនសរុប ដកចំនួនប្រជាជនដែលមិនទាន់មានការងារ( ក្រោម១៥ឆ្នាំ ) និងប្រជាជនដែលគ្រប់អាយុចូលបំពេញការងារ ( ១៥-៥៩ឆ្នាំ )

**ចំនួនប្រជាជនសរុប-(អាយុមិនទាន់មានការងារ+គ្រប់អាយុចូលបំពេញការងារ) = អាយុចូលនិវត្តន៍ ។**

តាមតួរលេខគេសង្កេតឃើញថា ប្រជាជនដែលមិនទាន់មានការងារធ្វើមានចំនួន ៤ ៥៧២ ៣៥០នាក់ ឬ ២៩.៤% និងប្រជាជនដែលគ្រប់អាយុចូលបំពេញការងារមានចំនួន ៩ ៥៩៥ ៧១៤នាក់ មានអាយុចូលនិវត្តន៍ គឺមានចំនួន ១ ៣៨៤ ១៤៧នាក់ ឬ ៨.៩% ស្រីមានចំនួន ៨២២ ៤៧១នាក់ ឬ ១០.៤% នៃ ចំនួនប្រជាជនសរុបទូទាំងប្រទេស។

រូ.ទី៣៖ ភាគរយប្រជាជនតាមវ័យ



# II. ទីផ្សារការងារ

លទ្ធផលជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថា អត្រាអ្នកមានការងារធ្វើនៅកម្ពុជាមាន ៩៨.៨% ធៀបទៅនឹងចំនួនប្រជាជនសរុប ប្រមាណ ១៥.៥លាននាក់។ អត្រាអ្នកគ្មានការងារធ្វើបានធ្លាក់ចុះមកត្រឹម ១.៣% ។

អ្នកមានការងារធ្វើនៅក្នុងសេដ្ឋកិច្ចកម្ពុជា ភាគច្រើនមានមុខរបរជំនាញខាងកសិកម្ម ដែលមានប្រមាណ ៥៣.៤% ដែលនេះបញ្ជាក់ថា ទីផ្សារនៅកម្ពុជាហាក់មិនទាន់មានជំនាញ និងត្រូវការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញការងារសម្រាប់ការប្រកួតប្រជែងទីផ្សារការងារ។ តាមរយៈលទ្ធផលនៃការធ្វើជំរឿន រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ជាខេត្តដែលមានសក្តានុពលការងារ និងការអភិវឌ្ឍខ្ពស់ ចំណែកឯខេត្តបន្ទាយមានជ័យ នៅតែជាគោលដៅទាក់ទាញយកការធ្វើចំណាកស្រុកមកពីបណ្តាខេត្តផ្សេង សម្រាប់ឱកាសការងារ សេដ្ឋកិច្ច និងការអភិវឌ្ឍ ជាពិសេសក្រុងប៉ោយប៉ែត។ សម្រាប់តំបន់ខ្ពង់រាប និងតំបន់ភ្នំមានរបាយប្រជាជនកើនឡើងតិចសម្រាប់ឱកាសការងារ ចំណែកតំបន់ទន្លេសាបហាក់មានការធ្លាក់ចុះ។

## ១-ស្ថិតិការងារ

យោងតាមរបាយការណ៍អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩ក្រសួងផែនការបានបង្ហាញថា ស្ថិតិការងារនៅកម្ពុជាតាមការបែងចែកជារួមមាន ការងារក្រៅប្រព័ន្ធការងារ ក្នុងប្រព័ន្ធការងារតាមមុខរបរ និងការងារតាមសកម្មភាពសេដ្ឋកិច្ច។ ស្ថិតិការងារនៅកម្ពុជាសរុប មានចំនួនប្រមាណ(២) ៧ ៨៨៣ ១០៦នាក់ អ្នកធ្វើការងារក្រៅប្រព័ន្ធមានចំនួន ៦ ៩៦០ ០៦០នាក់ និងអ្នកធ្វើការងារក្នុងប្រព័ន្ធមានចំនួន ៩២៣ ០៤៦នាក់។ ស្ថិតិការងារតាមមុខរបរគេសង្កេតឃើញជាអាទិ៍មាន ចំនួនតាមមុខរបរដែលជាគោល(៣)ដូចខាងក្រោម៖

- អ្នកគ្រប់គ្រងចំនួន ១២៨ ១២៨នាក់
- អ្នកមានវិជ្ជាជីវៈចំនួន ៣២៧ ៣៥៨នាក់
- អ្នកបច្ចេកទេស និងវិជ្ជាជីវៈរងចំនួន ២៩១ ៣៤៧នាក់
- អ្នកជំនួយការសៀនចំនួន ១២៤ ០០២នាក់
- អ្នកផ្តល់សេវាកម្ម និងលក់ចំនួន ១ ៦៨៨ ២៦៩នាក់
- អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ២ ២៦៣ ២៥៨នាក់
- អ្នកធ្វើអាជីវកម្ម និងអាជីវកម្មពាក់ព័ន្ធ ចំនួន ១ ៨០៧ ៣២១នាក់
- ការីម៉ាស៊ី និងរោងចក្រ និងអ្នកផ្គុំដំឡើង ចំនួន ៣៩៥ ៥១៨នាក់
- អ្នកធ្វើមុខរបរងាយៗចំនួន ៧៧៨ ៨៣០នាក់
- កងកម្លាំងប្រដាប់អាវុធកងកម្លាំងប្រដាប់អាវុធ ចំនួន ៧៩ ០៧៤នាក់។

(២) របាយការណ៍អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ទំព័រ៣៦

(៣) ប្រភេទមុខរបរមានក្នុងគោលខាងលើនេះ បានមកពី ចំណាត់ថ្នាក់មុខរបរអន្តរជាតិឆ្នាំ២០១៨ (ISCO-08)

តារាងទី២៖ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ តាមមុខរបរ

| មុខរបរ | ការងារក្រៅប្រព័ន្ធ | ការងារក្រៅប្រព័ន្ធ | សរុប | ការងាក្រៅប្រព័ន្ធ | ការងារក្រៅប្រព័ន្ធ | សរុប |
|---|---|---|---|---|---|---|
| | ចំនួន | | | % | | |
| អ្នកគ្រប់គ្រង | 81,038 | 47,090 | 128,128 | 63.2 | 36.8 | 100.0 |
| អ្នកមានវិជ្ជាជីវៈ | 196,968 | 130,390 | 327,358 | 60.2 | 39.8 | 100.0 |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈ | 204,690 | 86,657 | 291,347 | 70.3 | 29.7 | 100.0 |
| អ្នកជំនួយការស្មៀន | 91,499 | 32,503 | 124,002 | 73.8 | 26.2 | 100.0 |
| អ្នកផ្តល់សេវាកម្ម និងលក់ | 1,562,658 | 125,611 | 1,688,269 | 92.6 | 7.4 | 100.0 |
| កជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 2,232,412 | 30,846 | 2,263,258 | 98.6 | 1.4 | 100.0 |
| អ្នកធ្វើអាជីវកម្ម និងអាជីវកម្មពាក់ព័ន្ធ | 1,448,077 | 359,245 | 1,807,321 | 80.1 | 19.9 | 100.0 |
| ការីម៉ាស៊ី និងរោងចក្រ និងអ្នកផ្គុំដំឡើង | 364,279 | 31,239 | 395,518 | 92.1 | 7.9 | 100.0 |
| អ្នកធ្វើមុខរបរងាយៗ | 738,351 | 40,479 | 778,830 | 94.8 | 5.2 | 100.0 |
| កងកម្លាំងប្រដាប់អាវុធ | 40,086 | 38,988 | 79,074 | 50.7 | 49.3 | 100.0 |
| សរុប | 6,960,060 | 923,046 | 7,883,106 | 88.3 | 11.7 | 100.0 |

## ២-តម្រូវការទីផ្សារការងារ

ការជ្រើសរើសជំនាញ វាមិនខុសពីអាជីវកម្មទេ បើចង់ជោគជ័យលើវិស័យការងារណាមួយនោះគឺយើងចាំបាច់ត្រូវមើលពីតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននេះ និងទៅអនាគត ។ បើតាមការសង្កេតជាក់ស្តែងយើងឃើញថា បងប្អូនមួយចំនួនធំរើសជំនាញតាមគ្នា តាមមិត្តភក្តិ តាមគ្រួសារ មិនសូវបានមើលតម្រូវការទីផ្សារប៉ុន្មានទេ ប៉ុន្តែពេលនេះមិនថាបងប្អូនចង់ ឬមិនចង់យើងត្រូវរើសជំនាញណាដែលមានទីផ្សារល្អ និងមានប្រាក់ខែខ្ពស់ ។ យោងតាមការស្រាវជ្រាវបង្ហាញថា ជំនាញក្នុងវិស័យសំខាន់ៗចំនួន ១០ ដែលមិនទាន់អាចផ្គត់ផ្គង់ទីផ្សារ ឬតម្រូវការនៅកម្ពុជា។

នៅក្នុងវិស័យសំខាន់ៗទាំង១០ នៃសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និយោជកកំពុងប្រឈមការលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ដើម្បីបំពេញតាមតម្រូវការរបស់ខ្លួនដែលជាអាទិ៍រួមមាន៖

១.វិស័យសណ្ឋាគារ និងការស្នាក់នៅ,
២.វិស័យឡជីស្ទីក និងការដឹកជញ្ជូន,
៣.វិស័យសុខាភិបាល,
៤.វិស័យអប់រំ និងបណ្តុះបណ្តាល,
៥.វិស័យកែច្នៃម្ហូបអាហារ និងភេសជ្ជៈ,
៦.វិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង,
៧.វិស័យព័ត៌មានវិទ្យា,
៨.វិស័យសំណង់,
៩.វិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និង
១០.វិស័យផលិតកម្មកៅស៊ូ និងផ្លាស្ទិក។

លទ្ធផលអង្កេតបានបង្ហាញថា កត្តាចម្បងដែលនាំឱ្យនិយោជកជួបប្រទះការលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម គឺបណ្តាលមកពី បេក្ខជនគ្មានជំនាញបច្ចេកទេសតាមតម្រូវការ, មានការប្រកួតប្រជែងខ្លាំងក្នុងចំណោមនិយោជកក្នុងការជ្រើសរើស, កង្វះបទពិសោធន៍ការងារ, និងបេក្ខជន ដាក់ពាក្យស្វែងរកការងារមានចំនួនតិច។ ជំនាញសំខាន់ៗដែលអ្នកស្វែងរកការងារមានការខ្វះខាតរួមមាន៖ ជំនាញភាសាបរទេស, ជំនាញបច្ចេកទេស, ការបម្រើសេវាអតិថិជន, ការនិយាយស្តី, ការបំពេញការងារជាក្រុម, ការដោះស្រាយបញ្ហា និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។ លទ្ធផលនេះ បានបង្ហាញឱ្យឃើញថា ភាពមិនស៊ីគ្នានៃជំនាញនៅក្នុងទីផ្សារការងារកម្ពុជាបច្ចុប្បន្ន បណ្តាលមកពីកង្វះជំនាញរបស់អ្នកស្វែងរកការងារ និងទីផ្សារការងារ

ពុំទាន់ដំណើរការប្រកបដោយប្រសិទ្ធភាព។ លើសពីនេះលទ្ធផលអង្កេតក៏បានបង្ហាញឱ្យឃើញថា កម្មករនិយោជិតដែលកំពុងបំពេញការងារបច្ចុប្បន្នក៏ជួបប្រទះនូវគម្លាតជំនាញដែរ ពោលគឺមិនមានជំនាញគ្រប់គ្រាន់ សម្រាប់បំពេញតាម ការការងារនៃមុខតំណែងការងារដែលខ្លួនកំពុងធ្វើ។

## ៣-ទីផ្សារការងារតាមសកម្មភាពសេដ្ឋកិច្ច

តារាងទី៣៖ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមសកម្មភាពសេដ្ឋកិច្ច

| សកម្មភាពសេដ្ឋកិច្ច | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប |
|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 2,575,276 | 37,275 | 2,612,551 |
| រុករករ៉ែ និងថ្ម | 6,208 | 329,000 | 6,538 |
| ការផលិត | 920,826 | 394,140 | 1,314,966 |
| ផ្គត់ផ្គង់អគ្គសនី និងឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | 8,052 | 1,618 | 9,670 |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | 13,317 | 2,376 | 15,693 |
| សំណង់ | 763,492 | 21,718 | 785,210 |
| លក់ដុំ លក់រាយ ជួសជុលរថយន្ត | 1.242,892 | 76,135 | 1,319,027 |
| ដឹកជញ្ជូន និងស្តុកទំនិញ | 344,929 | 19,934 | 364,863 |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | 256,638 | 12,890 | 269,527 |
| ព័ត៌មាន និងទំនាក់ទំនង | 21,911 | 4,264 | 26,175 |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | 70,373 | 43,858 | 114,231 |
| សកម្មភាពអចលនទ្រព្យ | 20,459 | 4,664 | 25,123 |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | 45,281 | 15,297 | 60,579 |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | 151,084 | 25,738 | 176,821 |
| រដ្ឋបាលសាធារណៈ និងការពារសន្តិសុខសង្គមជាកាតព្វកិច្ច | 156,551 | 128,343 | 284,894 |
| អប់រំ | 101,328 | 81,644 | 182,972 |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | 33,260 | 31,473 | 64,733 |
| សិល្បៈ កម្សាន្ត និងសប្បាយ | 67,246 | 9,156 | 76,402 |
| សកម្មភាពសេវាកម្មដទៃទៀត | 123,795 | 7,866 | 131,662 |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មត្រូវផ្គត់ផ្គង់របស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | 32,178 | 1,818 | 33,996 |
| សកម្មភាពអង្គការ និងអង្គការក្រៅប្រទេស | 4,964 | 2,511 | 7,475 |
| សរុប | 6,960,060 | 923,046 | 7,883,106 |

# III. តម្រូវការកម្លាំងពលកម្ម

តម្រូវការកម្លាំងពលកម្មគឺជាចរន្តនៃការផ្លាស់ប្តូរ ឬលំហូរចេញចូលរវាងប្រជាជនដែលមានអាយុគ្រប់ចូលនិវត្យឬទុព្វលភាពតម្រូវការកម្លាំងពលកម្មដែលមានក្នុងទីផ្សារការងារប្រទេសកម្ពុជា។ កត្តាសិក្សាលើការស្វែងរកតម្រូវកម្លាំងពលកម្ម គឺត្រូវសិក្សាទៅលើចរន្តសេដ្ឋកិច្ចនៅក្នុងតំបន់ ចំនួនប្រជាជនចូលនិវត្យឬទុព្វលភាព និងចំនួនប្រជាជនដែលគ្រប់អាយុចូលបំពេញការងាររយៈពេល៤ឆ្នាំទៅមុខ។

៤ ៥៧២ ៣៥០នាក់ ស្រីមានចំនួន ២៧.៩% ស្មើនឹងចំនួនប្រជាជនប្រមាណជា ២ ៣២៥ ០៦២នាក់ នៃចំនួនប្រជាជនស្រីសរុបទូទាំងប្រទេស។

## ១-កំណើនកម្លាំងពលកម្មក្នុងទីផ្សារការងារ

យោងលើទិន្នន័យបានបង្ហាញថា(១) ប្រជាជនដែលមានអាយុចាប់ពី១៥ឆ្នាំ ដល់អាយុ១៨ឆ្នាំ មានប្រមាណជា ៧.២៨%ស្មើនឹងចំនួនប្រជាជនប្រមាណជា ១ ១៣២ ២០០នាក់ គិតរយៈពេល៤ឆ្នាំទៅមុខទៀត គឺឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ មានប្រជាជនប្រមាណជា ២៨៣,០៥០នាក់ ក្នុង១ឆ្នាំដែលត្រូវចូលក្នុងទីផ្សារការងារ។ ជាមួយគ្នានេះផងដែរ គេសង្កេតឃើញថា ប្រជាជនដែលមានអាយុចាប់ពី៥៥ឆ្នាំ ដល់អាយុ៥៩ មានប្រមាណជា ៤.១% ស្មើនឹងចំនួនប្រជាជនប្រមាណជា ៦៣៧,៦៤០នាក់ គិតរយៈពេល៤ឆ្នាំទៅមុខទៀត គឺឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ប្រជាជនប្រមាណជា ១២៧ ៥២៨នាក់ ក្នុង១ឆ្នាំដែលត្រូវចូលនិវត្តន៍។

## ២-តម្រូវការការងារ

បើអង្កេតតាមទិន្នន័យខាងលើយើងឃើញថា ប្រជាជនដែលពេញអាយុធ្វើការងារក្នុង១ឆ្នាំ មានចំនួនប្រមាណជា ២៨៣ ០៥០នាក់ និងប្រជាជនចូលនិវត្តន៍ក្នុង១មានចំនួនប្រមាណ ១២៧ ៥២៨នាក់។ បើយើងយកចំនួនប្រជាជនដែលពេញអាយុធ្វើការងារក្នុង១ឆ្នាំ ដកចំនួនប្រជាជនដែលចូលនិវត្តន៍ការងារក្នុង១ឆ្នាំ យើងនឹងរកឃើញចំនួនប្រជាជនដែលមាន

រូ.ទី៤៖តម្រូវការងារក្នុង១ឆ្នាំ




| | |
|---|---|
| ពេញអាយុធ្វើការងារ | ២៨៣ ០៥០ |
| ចូលនិវត្តន៍ | ១២៧ ៥២៨ |
| តម្រូវការការងារ | ១៥៥ ៥២២ |

## ៣-កំណើនកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច

គេសង្កេតឃើញថា ការងារសរុបបានកើនឡើងពី ៦ ៨២៨នាក់ ក្នុងឆ្នាំ២០០៧ ដល់ ៨ ៨០៥នាក់ ក្នុងឆ្នាំ២០២០ ក្នុងនោះចំនួនការងារស្ត្រីបានកើនពី ៣ ៣៥៤នាក់ ដល់ ៤ ៣១៨នាក់។ ការងារតាមវិស័យសេដ្ឋកិច្ចបង្ហាញថា ការងារក្នុងវិស័យកសិកម្មមានចំនួន ៥៧,៧% សេវាកម្មមានចំនួន២៧,៤% និងឧស្សាហកម្មមានចំនួន ១៤,៩% ក្នុងឆ្នាំ ២០០៧ ហើយក្នុងឆ្នាំ ២០២០ អ្នកធ្វើការក្នុងវិស័យកសិកម្មមានចំនួន ៣៥,៥% សេវាកម្មមានចំនួន ៣៨,៤% និងឧស្សាហកម្មមានចំនួន ២៦,១%។

(១) សៀវភៅជំរឿនឆ្នាំ២០១៩ ចេញផ្សាយក្នុងខែតុលា ឆ្នាំ២០២០ ទំព័រ៣៩

## តារាងទី៤៖ ការងារសរុប តាមភេទ និងវិស័យសេដ្ឋកិច្ច ឆ្នាំ២០០៧-២០២០

| | ចំនួនពលរដ្ឋមានការងារ (ពាន់នាក់) | | | ចំណែកការងារតាមវិស័យសេដ្ឋកិច្ច (ភាគរយ) | | |
|---|---|---|---|---|---|---|
| ឆ្នាំ | សរុប | ស្ត្រី | បុរស | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម |
| 2007 | 6,828 | 3,354 | 3,474 | 57.7 | 14.9 | 27.4 |
| 2008 | 7,837 | 3,332 | 4,505 | 58.9 | 14.6 | 26.5 |
| 2009 | 7,469 | 4,264 | 3,205 | 57.6 | 15.9 | 26.5 |
| 2010 | 7,673 | 3,867 | 3,806 | 54.2 | 16.2 | 29.6 |
| 2011 | 7,890 | 3,958 | 3,932 | 55.8 | 16.9 | 27.3 |
| 2012 | 7,706 | 3,781 | 3,925 | 51.0 | 18.6 | 30.4 |
| 2013 | 7,951 | 3,882 | 4,069 | 48.7 | 19.9 | 31.5 |
| 2014 | 8,235 | 3,968 | 4,267 | 45.3 | 24.3 | 30.4 |
| 2015 | 8,352 | 4,029 | 4,323 | 41.5 | 25.5 | 32.9 |
| 2016 | 8,608 | 4,167 | 4,441 | 36.4 | 26.6 | 37.0 |
| 2017 | 8,766 | 4,483 | 4,283 | 37.0 | 26.2 | 36.8 |
| 2019/2020 | 8,805 | 4,318 | 4,487 | 35.5 | 26.1 | 38.4 |




ឯកសារយោង៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ CSES (NIS 2021)

កម្រិតនៃការងារស្ត្រី គឺស្រដៀងនឹងការងារបុរសដែលយើង ដែលយើងសង្កេតឃើញការផ្លាស់ប្ដូរនិន្នាការនៃការងារស្ត្រីក្នុងផ្នែកកសិកម្មបានថយចុះពី ៥៩% ក្នុងឆ្នាំ២០០៧ មកត្រឹម ៣៨% ក្នុងឆ្នាំ២០២០ និងកើនឡើងពី ១៤% ទៅ ២៤% នៅក្នុងវិស័យឧស្សាហកម្ម និងពី ២៦% ទៅ ៣៨% ក្នុងវិស័យសេវាកម្ម។

តារាងទី៥៖ ការងារតាមវិស័យសេដ្ឋកិច្ច និងភេទ ឆ្នាំ២០០៧-២០២០ (ភាគរយ)

| ឆ្នាំ | ភេទ | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម |
|---|---|---|---|---|
| 2007 | ស្ត្រី | 59.4 | 14.3 | 26.3 |
| | ប្រុស | 56.1 | 15.5 | 28.4 |
| 2008 | ស្ត្រី | 55.5 | 15.9 | 28.6 |
| | ប្រុស | 55.7 | 15.7 | 28.6 |
| 2009 | ស្ត្រី | 60.4 | 15.4 | 24.2 |
| | ប្រុស | 61.2 | 14.2 | 24.6 |
| 2010 | ស្ត្រី | 55.4 | 15.5 | 29.1 |
| | ប្រុស | 52.9 | 17.0 | 30.1 |
| 2011 | ស្ត្រី | 56.6 | 17.5 | 26.0 |
| | ប្រុស | 55.0 | 16.3 | 28.7 |
| 2012 | ស្ត្រី | 52.8 | 18.1 | 29.1 |
| | ប្រុស | 49.3 | 19.0 | 31.7 |
| 2013 | ស្ត្រី | 50.0 | 19.2 | 30.8 |
| | ប្រុស | 47.4 | 20.5 | 32.1 |
| 2014 | ស្ត្រី | 46.7 | 24.1 | 29.2 |
| | ប្រុស | 43.9 | 24.5 | 31.5 |
| 2015 | ស្ត្រី | 43.9 | 24.8 | 31.2 |
| | ប្រុស | 39.4 | 26.1 | 34.4 |
| 2016 | ស្ត្រី | 39.3 | 25.2 | 35.5 |
| | ប្រុស | 33.7 | 27.9 | 38.4 |
| 2017 | ស្ត្រី | 35.1 | 27.3 | 37.6 |
| | ប្រុស | 39.0 | 25.1 | 35.9 |
| 2020 | ស្ត្រី | 38 | 24.2 | 37.8 |
| | ប្រុស | 33 | 27.9 | 39.1 |




ឯកសារយោង៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ CSES (NIS 2021)

តារាងទី៦៖ បម្រែបម្រួលនិងកំណើនការងារតាមវិស័យសេដ្ឋកិច្ច ឆ្នាំ២០០៧-២០២០

| ឆ្នាំ | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម | សរុប |
|---|---|---|---|---|
| 2007 | 3,941 | 1,018 | 1,869 | 6,828 |
| 2020 | 3,126 | 2,298 | 3,381 | 8,805 |
| បម្រែបម្រួល | -816 | 1,280 | 1,512 | 1,977 |
| កំណើន | -21% | 126% | 81% | 29% |

ឯកសារយោង៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ CSES ( NIS 2021 )

ការងារក្នុងវិស័យកសិកម្មបានចាប់ផ្តើមធ្លាក់ចុះតាំងពីឆ្នាំ២០១២ ហើយការធ្លាក់ចុះសរុបគឺ ២១% ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០២០។ ជាមួយនឹងការថយចុះការងារក្នុងវិស័យកសិកម្មជាង ៨១៦ពាន់នាក់ ដែលការធ្លាក់ចុះត្រូវបានបំពេញភាគច្រើនដោយការកើនឡើងនៃការងារក្នុងវិស័យសេវាកម្មនិងឧស្សាហកម្មរៀងៗខ្លួនចំនួន ១,២៨ លាននាក់ និង ១,៥១ លាននាក់។ ជាលទ្ធផលក្នុងឆ្នាំ ២០២០ ការងារក្នុងវិស័យសេវាកម្មមានចំនួន ៣៨,៤% ពោលគឺច្រើនជាងវិស័យកសិកម្មបន្តិចបន្តួចដែលមានចំនួន ៣៥,៥% គិតរយៈពេល៤ឆ្នាំទៅមុខទៀត គឺឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ខណៈដែលការងារក្នុងវិស័យឧស្សាហកម្មបានកើនឡើងដល់ ២៦,១%។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០២០ ការងារថ្មី ២៦,១%។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០២០ ការងារថ្មី ២ លានការងារ ត្រូវបានបង្កើតឡើង ហើយការងារសរុបបានកើនឡើង ២៩%។

ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ទីផ្សារការងារនៅប្រទេសកម្ពុជាមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់។ ក្នុងឆ្នាំ២០០៧ ប្រភេទការងារច្រើនបំផុត គឺអ្នកធ្វើការឱ្យខ្លួនឯងដែលមានចំនួន ៣៨% បន្ទាប់មកបុគ្គលិកគ្រួសារដែលគ្មានប្រាក់បៀវត្សរ៍ (៣៦%) និងនិយោជិតដែលមានបៀវត្សរ៍មានចំនួនត្រឹមតែ ២៦%។ នៅឆ្នាំ២០១៧ ភាគរយនៃនិយោជិតដែលមានបៀវត្សរ៍មានចំនួនរហូតដល់៥១% អ្នកធ្វើការឱ្យខ្លួនឯងបានកើនឡើងដល់ ៤៥% រីឯបុគ្គលិកគ្រួសារដែលគ្មានបៀវត្សរ៍ធ្លាក់ចុះមកត្រឹម ៤%។

ក្នុងឆ្នាំ២០០៧ ជាងពាក់កណ្តាលនៃការងារត្រូវបានចាត់ថ្នាក់ជាកម្មករកសិកម្មជំនាញ តែបានធ្លាក់ចុះមកត្រឹម ៣១% នៅក្នុងឆ្នាំ២០១៧។ ទន្ទឹមនឹងនេះ ភាគរយនៃសិប្បករដែលមានចំនួនតិចជាង ១០% បានកើនឡើងទ្វេដងហើយគិតមកទល់ពេលនេះមាន ២៤% គឺជាក្រុមមុខរបរធំជាងគេទីពីរ ហើយបុគ្គលិកផ្នែកលក់និងបុគ្គលិកសេវាកម្មបានកើនឡើងពី ១២% ទៅ ១៨%។ ទិន្នន័យស្តីពីមុខរបរក៏បញ្ជាក់ពីវត្តមាននៃកម្មករដែលគ្មានជំនាញ និងទាមទារឱ្យមានការអប់រំខ្ពស់។

គួរកត់សម្គាល់ថា បរិមាណអ្នកគ្រប់គ្រង អ្នកជំនាញ និងអ្នកបច្ចេកទេសបានធ្លាក់ចុះបន្តិចហើយនៅតែទាបជាង ៦%។ ទោះយ៉ាងណាក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ការរីកចម្រើននៃសិប្បកម្មនិងមុខរបរពាក់ព័ន្ធ មានចំនួន ៥៤% សេវាកម្មនិងអ្នកលក់ មានចំនួន ១៨% ស្មៀន មានចំនួន១៣% នៃកំណើនការងារ ខណៈការចូលរួមពាក់ព័ន្ធផ្សេងទៀតបានមកពីអ្នកដាំដុះ និងអ្នកជំនាញផ្នែកម៉ាស៊ីននិងអ្នកបច្ចេកទេស។

ទិន្នន័យស្តីពីការអប់រំបញ្ជាក់ថា ការងារនៅប្រទេសកម្ពុជានៅតែប្រឈមនឹងកង្វះខាតនៃការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស។ នៅឆ្នាំ២០០៧ កម្លាំងពលកម្មជិត ៨២% មិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចទេមានតែ ៤,៦% ប៉ុណ្ណោះដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង ២,១% ដែលមានសញ្ញាប័ត្រឧត្តមសិក្សា។ លើសពីនេះទៅទៀត ១៨% មិនមានការអប់រំជាផ្លូវការឡើយ។ បន្ទាប់ពីរយៈពេល ១០ឆ្នាំ

ស្ថានការណ៍បានប្រសើរឡើងពិតមែន ប៉ុន្តែកម្រិតអប់រំនៃកម្លាំងពលកម្មនៅទាបនៅឡើយគឺ ៧០% មិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចឡើយ។ អ្នកដែលមានការអប់រំខ្ពស់គឺ ៨% និង ៧% មានសញ្ញាប័ត្រក្រោយមធ្យមសិក្សា។ ជាវិជ្ជមានដែលថាក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ៣៤% នៃការងារបន្ថែមត្រូវបានស្រូបយកដោយអ្នកដែលមានការអប់រំក្រោយមធ្យមសិក្សា។ ទោះជាយ៉ាងណាក្នុងរយៈពេលដូចគ្នានេះ ក៏មានការកើនឡើងចំនួននៃការងារដែលមានការអប់រំកម្រិតក្រោមបឋម ឬបឋម។

# IV.តម្រូវការបណ្តុះបណ្តាលកម្លាំងពលកម្មតាមវិស័យ

## ១-ស្ថិតិសិស្ស និស្សិត

តាមរបាយការណ៍សន្និបាតរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំសិក្សា ២០២០-២០២១សិស្សានុសិស្សបានចូលរៀនតាមអនុវិស័យទទួលបានលទ្ធផលសម្រេចបានដូចខាងក្រោម(៥)៖

### ក. អនុវិស័យ ការអប់រំកម្រិតបឋម

សិស្សានុសិស្សសិក្សានៅថ្នាក់បឋមសិក្សា (ថ្នាក់ទី១ ដល់ថ្នាក់ទី៦) មានចំនួនសរុប ២ ១២៨ ៧២២នាក់ ស្រីមាន ១ ០២២ ៦៣០នាក់។ សិស្សបឋមសិក្សាសាធារណៈមាន ២ ០១០ ២៨៦នាក់ ស្រី ៩៦៤ ១៥២នាក់ ស្មើ ៤៨,០% ថយ ១៣ ១៨៧នាក់ ស្រី ៥ ៩០១នាក់ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០។ សិស្សបឋមសិក្សាឯកជនមានចំនួន ១១៨ ៤៣៦នាក់ ស្រី ៥៨ ៤៧៨នាក់ ស្មើ ៤៩,៤% ថយ ១៩ ២០១នាក់ ស្រីថយ ៩ ៥១៦នាក់។ អត្រាពិតចូលរៀនថ្មីសរុប ៨៧,៤% ស្រី ៨៨,០% ថយ ៩,០% ស្រីថយ ៨,៣% ក្នុងសាធារណៈ ៨២,៧% ស្រី ៨៣,៣% ថយ ៨,០% ស្រីថយ ៧,២% និងឯកជន ៤,៧% ស្រី ៤,៧% ថយ ១,០% ស្រីថយ ១,១%។ អត្រាពិតនៃការសិក្សាសរុប ៩១,៩% ស្រី ៩២,៣% ថយ ៥,៤% ស្រីថយ ៥,៦% ក្នុងនោះសាធារណៈ ៨៦,៧% ស្រី៨៧,០% ថយ ៤,៣% ស្រីថយ ៤,៤% និងឯកជន ៥,២% ស្រី ៥,៣% ថយ ១,១% ស្រីថយ ១,២%។

**អត្រាលំហូរសិស្ស**

អត្រាឡើងថ្នាក់ថយមកត្រឹម ៨៥,៧% ស្រី ៨៧,៩% និងប្រុស ៨៣,៦%។ អត្រាត្រួតថ្នាក់បានកើនដល់ ៧,០% ស្រីថយ ៥,៣% និងប្រុសកើនដល់ ៨,៧%។ អត្រាបោះបង់ការសិក្សាបានកើនដល់ ៧,៣% ស្រី ៦,៨% និងប្រុសនៅដដែល ៧,៧%។

(៥) របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩-២០២០

តារាងទី៧៖ អត្រាលំហូរសិស្ស

| បរិយាយ | | អត្រាលំហូរ (សរុប) | | | អត្រាលំហូរ (ស្រី) | | | អត្រាលំហូរ (ប្រុស) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| ២០១៩-២០ | ថ្នាក់ជាតិ | ៨៥,៧ | ៧,០ | ៧,៣ | ៩៧,៩ | ៥,៣ | ៦,៨ | ៤៣,៦ | ៨,៧ | ៧,៧ |
| | ប្រជុំជន | ៨៧,៣ | ៥,៨ | ៧,០ | ៨៩,៤ | ៤,៣ | ៦,៣ | ៨៥,៦ | ៧,១ | ៧,៥ |
| | ជនបទ | ៨៥,៤ | ៧,៣ | ៧,៣ | ៨៧,៦ | ៤,៥ | ៦,៩ | ៨៣,៣ | ៩,០ | ៧,៧ |
| ២០១៨-១៩ | ថ្នាក់ជាតិ | ៨៦,៩ | ៦,៣ | ៦,៨ | ៨៩,៥ | ៤,៧ | ៥,៩ | ៨៤,៥ | ៧,៨ | ៧,៧ |
| | ប្រជុំជន | ៨៩,៥ | ៤,៨ | ៥,៧ | ៩១,៩ | ៣,៤ | ៤,៧ | ៨៧,២ | ៦,១ | ៦,៧ |
| | ជនបទ | ៨៦,៤ | ៦,៦ | ៧,០ | ៨៩,០ | ៤,៩ | ៦,១ | ៨៣,៩ | ៨,២ | ៧,៩ |

### អត្រាបញ្ចប់ការសិក្សា

អត្រាបញ្ចប់កាសិក្សាមាន ៨៧,៤% ស្រី ៩១,៦% និងប្រុស ៨៣,៤%។

តារាងទី៨៖អត្រាបញ្ចប់កាសិក្សាឆ្នាំសិក្សា ២០១៩-២០២០ និង ២០២០-២០២១

| បរិយាយ | អត្រាបញ្ចប់ការសិក្សា ២០១៩-២០២០ | | | អត្រាបញ្ចប់ការសិក្សា ២០២០-២០២១ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ថ្នាក់ជាតិ | ៨៨,២ | ៩២,៧ | ៨៤,១ | ៨៧,៤ | ៩១,៦ | ៨៣,៤ |
| ប្រជុំជន | ៩៤,០ | ៩៨,៧ | ៩៨,៧ | ៩៣,៩ | ៩៨,៣ | ៨៩,៨ |
| ជនបទ | ៨៦,៧ | ៩១,០ | ៨២,៧ | ៨៥,៧ | ៩០,០ | ៨១,៧ |

## ២. អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

ក្នុងឆ្នាំសិក្សា ២០២០-២០២១ សិស្សានុសិស្សសិក្សានៅកម្រិតអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេសមានចំនួនសរុប ១ ០៤៨ ៦៥៣នាក់ ស្រី ៥៦០ ១៣១នាក់ មានកំណើនសរុបចំនួន ៣២ ៣៤៥នាក់ ស្រី ១៩ ៤៤២នាក់ បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០។ សិស្សអប់រំមធ្យមសិក្សាសាធារណៈ មានចំនួនសរុប ៩៨៤ ០៩៧នាក់ ស្រី ៥២៧ ៩៤៥នាក់ ក្នុងនោះសិស្សសិក្សានៅមធ្យមសិក្សាបឋមភូមិ មានចំនួនសរុប ៦៣២ ៣០៣នាក់ ស្រី ៣៣៥ ៩៧២នាក់ និងសិស្សសិក្សានៅមធ្យមសិក្សាទុតិយភូមិ មានចំនួនសរុប ៣៥១ ៧៩៤នាក់ ស្រី ១៩១ ៩៧៣នាក់។ ចំពោះសិស្សអប់រំមធ្យមសិក្សាឯកជន មានចំនួនសរុប ៦១ ២៣២នាក់ ស្រី ៣០ ៩១៧នាក់ ក្នុងនោះ សិស្សសិក្សានៅមធ្យមសិក្សាបឋមភូមិ មានចំនួនសរុប ៣៦ ៣៣៤នាក់ ស្រី ១៨ ៣៤១នាក់ និងសិស្សសិក្សានៅមធ្យមសិក្សាទុតិយភូមិ មានចំនួនសរុប ២៤ ៨៩៨នាក់ ស្រី ១២ ៥៧៦នាក់។ ចំណែកសិស្សសិក្សានៅចំណេះទូទៅនិងបច្ចេកទេស មានចំនួនសរុប ៣ ៣២៤នាក់ ស្រី ១ ២៦៩នាក់។

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦០,៧០% កើន ០,៨០% ស្រី ៦៦,៦០% កើន ១,៥០% ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៥៧,៤០% ស្រី ៦៣,២០% និងឯកជន ៣,៣០% ស្រី ៣,៤០%។ អត្រាភូមិសិក្សានៅមធ្យមសិក្សាបឋមភូមិ ៨១,៣០% កើន ៦,៤០% ស្រី ៨២,៤០% កើន ៣,៨០%។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ៣២,២០% កើន ១,៣០% ស្រី ៣៦,៤០% កើន ១,៣០% ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៣០,១០% ស្រី ៣៤,២០% និងឯកជន ២,១០% ស្រី ២,២០%។

តារាងទី៩៖ ស្ថិតិមធ្យមសិក្សាប្រៀបធៀបរវាងឆ្នាំសិក្សា ២០១៩-២០២០ និង ២០២០-២០២១

| បរិយាយ | ២០១៩-២០២០ | | ២០២០-២០២១ | | កើន/ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| បឋមភូមិ | ៦៥៥ ០៥៥ | ៣៨៤ ០៥០ | ៦៦៨ ៦៣៧ | ៣៥៤ ៩៧២ | +១៣ ៥៨២ | +១០ ២៦៣ |
| សាធារណៈ | ៦១៨ ៩៦៨ | ៣២៥ ៥០៤ | ៦៣២ ៣០៣ | ៣៣៥ ៩៧២ | +១៣ ៣៣៥ | +១០ ៤៦៨ |
| ឯកជន | ៣៦ ០៦៧ | ១៨ ៥៤៦ | ៣៦ ៣៣៤ | ១៨ ៣៤១ | +២៧៤ | -២០៥ |
| ទុតិយភូមិ | ៣៥៨ ៥៥៣ | ១៩៥ ៦០៣ | ៣៧៦ ៦៩២ | ២០៤ ៥៤៩ | +១៨ ១៣៩ | +៨ ៩៤៦ |
| សាធារណៈ | ៣៣៤ ៧១២ | ១៨៣ ៣៩៤ | ៣៥១ ៧៩៤ | ១៩១ ៩៧៣ | +១៧ ០៨២ | +៨ ៥៧៩ |
| ឯកជន | ២៣ ៨៤១ | ១២ ២០៩ | ២៤ ៨៩៨ | ១២ ៥៧៦ | +១ ០៥៧ | +៣៦៧ |
| ចំនេះដឹងទូទៅនិងបច្ចេកទេស | ២ ៧០០ | ១ ០៣៦ | ៣ ៣២៤ | ១ ២៦៩ | +៦២៤ | +២៣៣ |
| សរុបសាធារណៈ | ៩៥៣ ៦៨០ | ៥០៦ ៨៩៨ | ៩៨៤ ០៩៧ | ៥២៧ ៩៤៥ | +៣០ ៤១៧ | +១៩ ០៤៧ |
| សរុបឯកជន | ៥៨ ៩២៨ | ៣០ ៧៥៥ | ៦១ ២៣២ | ៣០ ៩១៧ | +១ ៣០៤ | +១៦២ |
| សរុបរួម | ១ ០១៦ ៣០៨ | ៥៤០ ៦៨៩ | ១ ០៤៨ ៥៦៣ | ៥៦០ ១៣១ | +៣២ ៣៤៥ | +១៩ ៤៤២ |

### អត្រាលំហូរសិស្ស

-អត្រាឡើងថ្នាក់មធ្យមសិក្សាបឋមភូមិកើន ២,៨០% ស្រីកើន ១,៩០% និងមធ្យមសិក្សាទុតិយភូមិកើន ៩,៩០% ស្រីកើន ៧,៦០%

-អត្រាត្រួតថ្នាក់មធ្យមសិក្សាបឋមភូមិថយ ២,៤០% ស្រីថយ ១,៣០% និងមធ្យមសិក្សាទុតិយភូមិថយ ១,៤០% ស្រីថយ ០,៩០%

-អត្រាបោះបង់ការសិក្សាមធ្យមសិក្សាបឋមភូមិថយ ០,៤០% ស្រីថយ ០,៥០% និងមធ្យមសិក្សាទុតិយភូមិថយ ៨,៥០% ស្រីថយ ៦,៧០%។

តារាងទី១០៖ អត្រាលំហូរសិស្សនៅមធ្យមសិក្សារវាងឆ្នាំសិក្សា ២០១៨-២០១៩ និង ២០១៩-២០២០

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|
| | ២០១៨-២០១៩ | ២០១៩-២០២០ | កើន/ថយ | ២០១៨-២០១៩ | ២០១៩-២០២០ | កើន/ថយ |
| អត្រាឡើងថ្នាក់ | +៧៨,៦ | +៨១,៤ | +២,៨ | +៨១,៥ | +៩១,៤ | +៩,៩ |
| អត្រាត្រួតថ្នាក់ | +២,៩ | +០,៤ | -២,៤ | +១,៦ | +០,២ | -១,៤ |
| អត្រាបោះបង់ការសិក្សា | +១៨,៦ | +១៨,២ | -០,៤ | +១៦,៩ | +៨,៤ | -៨,៥ |
| អត្រាឆ្លងភូមិសិក្សា | +៨៥,០ | ៨៤,៣ | ០,៧ | +៧៤,៩ | +៨១,៣ | -៦,៤ |

## គ. អនុវិស័យ ការអប់រំឧត្តមសិក្សា

ក្នុងឆ្នាំសិក្សា ២០២០-២០២១ និស្សិតកំពុងសិក្សានៅឧត្តមសិក្សាទាំងអស់មានចំនួន ២០១ ៩០០នាក់ ស្រី ១០២ ៥៩៩នាក់ស្មើ ៥០,៨០% ក្នុងនោះនិស្សិតបរទេស ១៥៥នាក់ ស្រី ៧១នាក់ស្មើ ៤៥,៨០% បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០ និស្សិតថយចុះ ២០ ៩៧៩នាក់ ស្មើ៩,៤០%។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង មានចំនួន ១៩ ៧៨២នាក់ ស្រី ១០ ២៣៩នាក់ ស្មើ ៥១,៧៦% ប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩ កើន ២០៧នាក់ ស្រី ១០៦នាក់ ស្មើ ០,៥០%។ ចំពោះនិស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង មានចំនួន ៨ ១៨៤នាក់ ស្រី ៤ ៣៦០នាក់ ស្មើ ៥៣,២៧% ប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩ កើន ១៧៤នាក់ ស្រី ១៧១នាក់ ស្មើ ៤,០៨%។

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ មានចំនួន ១៧១ ១៨៣នាក់ ស្រី ៩២ ២៣៧នាក់ ស្មើ ៥៣,៨៨% បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩ ថយ ៨ ០៧៥នាក់ ស្មើ ៤,៥០% ស្រីកើន ១ ៣០៤នាក់ ស្មើ ១,៤៣%។ ចំពោះនិស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ មានចំនួន ៣២ ៦៤០ នាក់ ស្រី ១៦ ៤៨២នាក់ ស្មើ ៥០,៤៩% បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩ ថយ ៦ ០៦៩ នាក់ ស្មើ ១៥,៦៧% ស្រី ៣ ៨៥៨នាក់ ស្មើ ១៨,៩៦%។

និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ មានចំនួន ១០ ៩៤៥នាក់ ថយ ៥៤,៤៨% ស្រី ៣ ១២៣នាក់ ស្មើ ២៨,៥៣% ៩៦១នាក់ ស្រី ៨៨នាក់ ស្មើ ៩,១៦% បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថយ ៥៧,០៧% និស្សិតថ្នាក់បណ្ឌិត កើន ២១,៦០%។ ចំពោះនិស្សិតបានបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ មានចំនួន ៣២ ៦៤០នាក់ ស្រី ១៦ ៤៨២នាក់ ស្មើ ៥០,៤៩% បើប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩ ថយ ៦ ០៦៩ នាក់ ស្មើ ១៥,៦៧% ស្រី ៣ ៨៥៨នាក់ ស្មើ ១៨,៩៦%។

តារាងទី១១៖ ស្ថានភាពនិស្សិតកំពុងសិក្សា និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យ ក្នុងឆ្នាំសិក្សា ២០១៩-២០២០

| ល.រ | បរិយាយ | កំពុងសិក្សា | បញ្ចប់ការសិក្សា |
|---|---|---|---|
| ១ | ធុរកិច្ច (គណនេយ្យ សេដ្ឋកិច្ច ធនាគារ ហិរញ្ញវត្ថុ គ្រប់គ្រង) | ៤២% | ៣៧% |
| ២ | សុខាភិបាល | ៥% | ៥% |
| ៣ | កសិកម្ម | ៣% | ៤% |
| ៤ | វិស្វកម្ម | ៨% | ៨% |
| ៥ | វិទ្យាសាស្ត្រមូលដ្ឋាន | ៥% | ៦% |
| ៦ | បច្ចេកវិទ្យាព័ត៌មាន | ៩% | ១០% |
| ៧ | វិទ្យាស្ថានសង្គម និងសិល្បៈ | ៩% | ១០% |
| ៨ | ទេសចរណ៍ | ២% | ២% |
| ៩ | ច្បាប់ | ៧% | ៨% |
| ១០ | ភាសាបរទេស | ១០% | ១០% |

រូ.ទី៥៖ ស្ថានភាពនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យក្នុងឆ្នាំសិក្សា ២០១៩-២០២០




រូ.ទី៦៖ ស្ថានភាពនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យក្នុងឆ្នាំសិក្សា ២០១៩-២០២០



## ២-ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ

បច្ចុប្បន្ន ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានគ្រឹះស្ថានសិក្សាក្រោមឱវាទចំនួន ១១០ ក្នុងនោះ គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ចំនួន ៣៨ គ្រឹះស្ថានសិក្សាឯកជន ចំនួន ៤៧ និងអង្គការសមាគម ចំនួន ២៥។ គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ បាននិងកំពុងផ្ដល់ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ នៅគ្រប់កម្រិតសិក្សា លើវគ្គសិក្សារយៈពេលខ្លី និងរយៈពេលវែង (ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) សិក្សាចល័ត និង កម្មវិធីបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ លើជំនាញជាច្រើនដូចជា៖

១. វិស័យសំណង់៖ សំណង់ស៊ីវិល ស្ថាបត្យកម្ម ការងារកំបោរ ការដំឡើងសសៃដែក ការដំឡើងពុម្ព ការដំឡើងគ្រឿងឈើសម្រេច ការដំឡើងបណ្ដាញបំពង់ទឹក ការដំឡើងបណ្ដាញអគ្គិសនីក្នុងអគារ ការដំឡើងគ្រោងដែក ការលាបថ្នាំអគារ ការងារបេតុង ការងារសំណង់អគារ ការដំឡើងដំបូល

២. វិស័យមេកានិក៖ វិស្វកម្មរថយន្ត មេកានិកទូទៅការថែទាំនិងជួសជុលរថយន្ត ការថែទាំនិងជួសជុលអគ្គិសនីរថយន្ត ការថែទាំនិងជួសជុលម៉ាស៊ីនត្រជាក់រថយន្តការថែទាំនិងជួសជុលទោចក្រយានយន្ត ការជួសជុលតួរថយន្ត ការថែទាំនិងបាញ់ថ្នាំរថយន្ត ការជួសជុលនិងកែឆ្នៃគ្រឿងបន្លាស់ម៉ាស៊ីនរថយន្ត ការថែទាំនិងជួសជុលម៉ាស៊ីនធុនតូច ការថែទាំនិងជួសជុលរថយន្តធុនធ្ងន់ការបញ្ជូថែទាំនិងជួសជុលគ្រឿងយន្តកសិកម្ម។ល

៣. វិស័យអគ្គិសនីនិងថាមពល៖ អគ្គិសនី អេឡិចត្រូនិក ការថែទាំនិងជួសជុលអគ្គិសនី (ទូទៅ) ការដំឡើងនិងថែទាំអគ្គិសនីក្នុងឧស្សាហកម្ម ការថែទាំនិងជួសជុលបរិក្ខារប្រើប្រាស់អគ្គិសនីក្នុងគេហដ្ឋាន ការដំឡើងនិងថែទាំបណ្ដាញបញ្ជូនថាមពលអគ្គិសនី ការដំឡើងនិងថែទាំបណ្ដាញអគ្គិសនី។ល។

៤. វិស័យធុរកិច្ច/ICT៖ ព័ត៌មានវិទ្យា ទូរគមនាគមន៍ គ្រប់គ្រងពាណិជ្ជកម្ម គណនេយ្យនិងហិរញ្ញវត្ថុ ធនាគារ និងហិរញ្ញវត្ថុ ម៉ាឃីតធីង ពាណិជ្ជកម្មអេឡិចត្រូនិច សេវាកម្មធនធានមនុស្ស សេវាកម្មរដ្ឋបាល សេវាកម្មអតិថិជន សេវាកម្មលក់ សេវាកម្មម៉ាខេតធីង សេវាកម្មធុរកិច្ច សេវាកម្មកុំព្យូទ័រ ការរចនាក្រាហ្វិកដោយកុំព្យូទ័រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច។ល។

៥. វិស័យកម្មន្តសាល៖ វិស្វកម្មលោហៈ ប្រព័ន្ធស្វ័យប្រវត្តិកម្មការផ្សារអគ្គិសនី ការបន្ស៊ីលោហៈ ការផលិតនំការកែច្នៃបន្លែនិងផ្លែឈើ ការថែទាំនិងជួសជុលបរិក្ខារមេកានិក ការផ្សារឧស្ម័ន ការដំឡើងនិងថែទាំប្រព័ន្ធមេកាត្រូនិក

៦. វិស័យបរិក្ខារត្រជាក់និងកំដៅ៖ បរិក្ខារត្រជាក់ សេវាកម្មបរិក្ខារត្រជាក់ក្នុងគេហដ្ឋាន សេវាកកម្មបរិក្ខារត្រជាក់ពាណិជ្ជកម្ម។ល។

៧. ជំនាញផ្សេងៗ៖ នីតិសាស្ត្រ អក្សរសាស្ត្រអង់គ្លេស ក្សេតសាស្ត្រ បសុព្យាបាល តបណ្ដាញទឹក ជួសជុលម៉ាស៊ីនគ្រប់ធន់ កាត់កញ្ចក់វ៉ែនតា (អុបទិក) កសិកម្ម និងកែច្នៃបន្លែផ្លែឈើ វិជ្ជាធ្វើម្ហូប ឆុងកាហ្វេ និងភេសជ្ជៈ ក្រឡុកស្រា កាត់ដេរសម្លៀកបំពាក់ សម្អាងការ និងសម្អាងកាយ និងជំនាញវិជ្ជាជីវៈជាច្រើនទៀត។

### ២.១ សិក្ខាកាម សិស្ស និស្សិតរៀនជំនាញបច្ចេកទេស

ស្ថិតក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ បានផ្អាកដំណើរការជាបន្តបន្ទាប់ ដែលជាហេតុនាំឱ្យការចុះឈ្មោះចូលរៀនប៉ុន្មានឆ្នាំចុងក្រោយនេះមានការធ្លាក់ចុះ។ ប៉ុន្តែបើទោះបីជាស្ថិតក្នុងស្ថានភាពបែបនេះក្ដី ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានខិតខំរកច្រកសិក្សាថ្មីមួយ ដើម្បីធានានិរន្តភាពនៃការបង្រៀន និងរៀនរបស់សាស្ត្រាចារ្យ សិក្ខាកាម សិស្ស និស្សិតអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការបង្កើតនូវច្រកសិក្សាបែបគន្លងថ្មី គឺប្រព័ន្ធជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយឬតាមអនឡាញ។ (សូមអានសេចក្ដីលម្អិតនៅទំព័របន្ទាប់)

តួយ៉ាង សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ មាន សិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សាសរុបចំនួន ៥០ ៦៩០នាក់ ស្រី ២២ ០១១នាក់ ថយចុះចំនួន ៥៦១នាក់ ស្មើនឹង ១,០៩% ស្រីថយចុះចំនួន ១ ៥២៤នាក់ ស្មើនឹង ៦,៤៨% បើប្រៀបធៀបនឆ្នាំសិក្សា ២០១៩-២០២០។

គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ សាធារណៈ មានចំនួនសរុប ៤១ ៤៤២នាក់ ស្រី ១៧ ៤១៧នាក់ កើនឡើងចំនួន ៣១០នាក់ ស្មើនឹង ០,៧៥% ស្រីថយចុះ ១ ២៥៣នាក់ ស្មើនឹង ៦,៧១% បើប្រៀបធៀបនឆ្នាំសិក្សា ២០១៩-២០២០។

គ្រឹះស្ថានសិក្សាឯកជន មានចំនួនសរុប ៤ ០៣៥នាក់ មានចំនួនសរុប ៤១ ៤៤២នាក់ ស្រី ១៧ ៤១៧នាក់ កើនឡើង ចំនួន៣១០នាក់ ស្មើនឹង ០,៧៥% ស្រីថយចុះ ១ ២៥៣នាក់ ស្មើនឹង ៦,៧១% បើប្រៀបធៀបនឆ្នាំសិក្សា ២០១៩-២០២០។

អង្គការ សមាគម មានចំនួនសរុប ៥ ២១៣នាក់ ស្រី ៣ ១៥៣នាក់ ថយចុះចំនួន ៥៩២នាក់ស្មើនឹង ១០,២០% ស្រីថយចុះ ២៧៥នាក់ ស្មើនឹង ៨,០២% បើប្រៀបធៀប និងឆ្នាំសិក្សា ២០១៩-២០២០។

តារាងទី១២៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិតបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថា អ.ប.វ. ឆ្នាំសិក្សា ២០២០-២០២១ ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០

| ល.រ | គ្រឹះស្ថាន អ.ប.វ | ឆ្នាំសិក្សា ២០១៩-២០២០ | | ឆ្នាំសិក្សា ២០២០-២០២១ | | កើន/ថយ(%) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | សាធារណៈ | ៤១ ១៣២ | ១៦ ៦៧០ | ៤១ ៤៤២ | ១៧ ៤១៧ | ០,៧៥ | -៦,៧១ |
| 2 | ឯកជន | ៣ ៣១៤ | ១ ៤៣៧ | ៤ ០៣៥ | ១ ៤៤១ | -៦,៤៨ | ០,២៨ |
| 3 | អង្គការ សមាគម | ៥ ៨០៥ | ៣ ៤២៨ | ៥ ២១៣ | ៣ ១៥៣ | -១០,២០ | -៨,០២ |
| សរុប | | ៥១ ២៥១ | ២៣ ៥៣៥ | ៥០ ៦៩០ | ២២ ០១១ | -១,០៩ | -៦,៤៨ |

សិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សាតាមកម្រិតគុណវុឌ្ឍិជាតិកម្ពុជាក្នុងឆ្នាំសិក្សា ២០២០-២០២១ រួមមាន៖

-កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សរុបចំនួន ១៧ ៤៦៧នាក់ ស្រី ៨ ៨៤៧នាក់

-កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ (C1) សរុបចំនួន ១២ ២៨៩នាក់ ស្រី ៥ ៥៩០នាក់

-កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ (C2) សរុបចំនួន ១ ៧៦៨នាក់ ស្រី ៥២៧នាក់

-កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ (C3) សរុបចំនួន ៦៦៤នាក់ ស្រី ១៥៩នាក់

-សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស សរុបចំនួន ៤ ៣៤៦នាក់ ស្រី ៩៥១នាក់

-បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ សរុបចំនួន ៤ ៨៤០នាក់ ស្រី ១ ៣៣០នាក់

-បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស សរុបចំនួន ៦៨នាក់ ស្រី ១៣នាក់។

តារាងទី១៣៖ ស្ថិតិសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សាតាមកម្រិតគុណវុឌ្ឍិជាតិកម្ពុជា ឆ្នាំសិក្សា ២០២០-២០២១ ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០

| កម្រិត | បរិយាយ | ឆ្នាំសិក្សា ២០១៩-២០២០ | | ឆ្នាំសិក្សា ២០២០-២០២១ | | កើន/ថយ(%) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | ០ | ០ | ០ | ០ | - | - |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ១២៣ | ២៣ | ៦៨ | ១៣ | -៤៤,៧២ | -៤៣,២២ |
| ៦ | បរិញ្ញាបត្រ បច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ | ៤ ៩១៦ | ២ ៤២៨ | ៤ ៨៤០ | ១ ៣៣០ | -១,៥៥ | -៤៥,២២ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | ៣ ៧៨៦ | ១ ២០៤ | ៤ ៣៤៦ | ៩៥១ | ១៤,៧៩ | -២១,០១ |
| ៤ | សញ្ញាបត្រ បច្ចេកទេស និងវិជ្ជាជីវៈ៣ | ៥៥៧ | ១០៦ | ៦៦៤ | ១៥៩ | ១៨,២១ | ៥០ |
| ៣ | សញ្ញាបត្រ បច្ចេកទេស និងវិជ្ជាជីវៈ២ | ៩៧០ | ២៣៤ | ១ ៧៦៨ | ៥២៧ | ៨២,២៧ | ១២០,៥០ |
| ២ | សញ្ញាបត្រ បច្ចេកទេស និងវិជ្ជាជីវៈ១ | ៣ ០៩៣ | ៩៨៣ | ១២ ២៨៩ | ៥ ៥៩០ | ២៩៨,៦០ | ៤៦៨,៦៧ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ២៧ ៦៧៩ | ១៣ ៦៨៧ | ១៧ ៤៦៧ | ៨ ៨៤៧ | -៣៦,៩៤ | -៣៥,៣៦ |
| | សរុប | ៤១ ១៣២ | ១៨ ៦៧០ | ៤១ ៤៤២ | ១៧ ៤១៧ | ០,៧៥ | -៦,៧១ |

សិក្ខាកាមបានបញ្ចប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈតាមប្រភេទកម្មវិធីផ្សេងៗរួមមាន៖

-កម្មវិធីស្ពានចម្លងបន្តជំនាញ សរុបចំនួន ១ ១៥២នាក់ ស្រី ៥៣៩នាក់

-កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ សរុបចំនួន ២ ៨២១នាក់ ២ ២៥៩នាក់

-កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណេត

-កម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋនិងឯកជន សរុបចំនួន ៩៦៧នាក់ ស្រី ៣២៩នាក់

-កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍-៤ខែ) សរុបចំនួន ១២ ៤០៧នាក់ ស្រី ៥ ៦៨៣នាក់។

តារាងទី១៤៖ ស្ថិតិសិក្ខាកាម បានបញ្ចប់កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈតាមប្រភេទកម្មវិធីផ្សេងៗ ឆ្នាំសិក្សា ២០២០-២០២១ ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៩-២០ | | ឆ្នាំសិក្សា ២០២០-២១ | | កើន/ថយ(%) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កម្មវិធីស្ពានចម្លងបន្តជំនាញ | ២ ៣១៩ | ១ ១៧៣ | ១ ១៥២ | ៥៣៩ | -៥០,៣២ | -៥៤,០៥ |
| ២ | កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ | ២ ៣១៩ | ៦ ៨២៣ | ២ ៨២១ | ២ ២៥៩ | -៧៧,១១ | -៦៦,៨៩ |
| ៣ | កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណេត (ប៊ីប/ BEEP) | ២០៥ | ៧៥ | ១២០ | ៣៧ | -៤១,៤៦ | -៥០,៦៧ |
| ៤ | កម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋនិងឯកជន | ៤៣៨ | ៣៤ | ៩៦៧ | ៣២៩ | ១២០,៧៨ | ៨៦៧,៦៥ |
| ៥ | កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍-៤ខែ) | ១២ ៤០៧ | ៥ ៥៨២ | ១២ ៤០៧ | ៥ ៦៨៣ | ០ | ១,៨១ |
| សរុប | | ២៧ ៦៧៩ | ១៣ ៦៨៧ | ១៧ ៤៦៧ | ៨ ៨៤៧ | -៣៦,៩៤ | -៣៥,៣៦ |

## ២.២ ការសិក្សាជំនាញបច្ចេកទេសតាមវិស័យ

ប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើននៃការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានការកើនឡើងគួរកត់សម្គាល់ ដោយសង្កេតឃើញថា យុវជន សិក្ខាកាម សិស្ស និស្សិត និងសាធារណជន ហាក់មានការចាប់អារម្មណ៍ខ្លាំងទៅលើការសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដែលកំពុងមានតម្រូវការខ្ពស់នៅលើទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស។ ក្នុងនោះ ក្រសួងការងារ និងណ្តុះបណ្តាលវិជ្ជាជីវៈ បានសិក្សាស្រាវជ្រាវ និងកំណត់បាននូវវិស័យអាទិភាព ក្នុងនោះសម្រាប់ឆ្នាំសិក្សា ២០២០-២០២១ សិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សាពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និង

វិជ្ជាជីវៈសរុបចំនួន ១៧ ២៩៦នាក់ ស្រី ៥ ៤៣៦នាក់ រួមមានជាអាទិ៍៖

- វិស័យអគ្គិសនីនិងថាមពល មានសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០២០-២០២១ សរុបចំនួន ៥ ១៧២នាក់ ស្រី ៧៣០នាក់
- វិស័យសំណង់ មានសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០២០-២០២១ សរុបចំនួន ២ ៩០៧នាក់ ស្រី ៤២៦នាក់
- វិស័យមេកានិក មានសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០២០-២០២១ សរុបចំនួន ១ ២៩៧នាក់ ស្រី ៧០នាក់
- វិស័យធុរកិច្ច/ICT មានសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០២០-២០២១ សរុបចំនួន ៦ ៨៨៣នាក់ ស្រី ៣ ៩៧១នាក់
- វិស័យកម្មន្តសាល មានសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០២០-២០២១ សរុបចំនួន ៦៥៣នាក់ ស្រី ២១៤នាក់
- វិស័យបរិក្ខារត្រជាក់និងកំដៅ មានសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០២០-២០២១ សរុបចំនួន ៣៨៥នាក់ ស្រី ២៥នាក់។

រូ.ទី៧៖ សិក្ខាកាម សិស្ស និស្សិត បានបញ្ចប់ការសិក្សាតាមវិស័យអាទិភាព ឆ្នាំសិក្សា ២០២០-២០២១



## ២.៣ ប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform)

ប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ គឺជាប្រព័ន្ធបច្ចេកវិទ្យាមួយដែលដើរតួរនាទីជាស្នូលដែលផ្ទុកនូវធនធានអប់រំបណ្តុះបណ្តាល និងផ្តល់មធ្យោបាយបន្ថែម សម្រាប់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យកាន់តែមានប្រសិទ្ធភាពទោះក្នុងបរិបទកូវីដ-១៩ និងពេលបន្ទាប់។




ធនធានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ០៥៥/២១ ក.ប/អ.វ.ប.ម.ប.វ

សេចក្តីជូនដំណឹង
ស្តីពី
ការដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform)

